# ផ្កាស្រពោន

**ភាគទី១២**

មានយប់មួយនៅវេលាអាធ្រាត្រនាងវិធារីដែលនិទ្រាមិនលក់សោះនោះ ក៏ក្រោកឡើងបើកបង្អួចក្បាលដំណេក។ ខ្យល់ត្រជាក់បោកបក់ក្លិនរុក្ខជាតិ ស៊ុះចូលមកអង្អែលកត្រានាង។ នៅខាងក្រៅ លោកខែបញ្ចាំងរស្មីទន់ត្រជាក់ដូចព្រៃមកគ្របលើសាកលទ្វីប។ នៅក្នុងមេឃពណ៌ខៀវផ្កាត្រយង់ ដុំពពកសៗដូចកប្បាសរសាត់បន្តគ្នា ជួនកាលមកបាំងវង់ព្រះច័ន្ទបណ្ដាលស្រទំស្ងប់មួយភ្លែតៗ កាលណាពពកនោះអណ្ដែតផុតទៅ ពន្លឺរាជនីនៃរាត្រីមកចាំលើជាងដូងដែលយោលពេរេដោយវាយោ ហើយដែលភ្លឺភ្លែតៗ ដូចជាបន្ទះដែកស្និត។

នៅក្នុងសន្ធិយាស្ងាត់នោះ នាងវិធារីនៅកណ្ដែងកណ្ដោចឈឺអួលផ្សាតែម្នាក់ឯង។ ចិត្តនាងនឹកទៅដល់ប៉ុនជឿនមិនលោះវេលា។ ឱម្ទេះនៅពេលមួយនេះ សមអ្នកបងនិទ្រាសុខសំរាន្ត ឬមួយក៏មានចិត្តគិតមកនាងខ្វះដែរក៏មិនដឹង។ នៅពេលដែលនាងគិតឃើញដូច្នេះ ទឹកភ្នែកពីរដំណក់ហូររមៀលចុះមក។ នាងនឹកដល់ពពួកទេវតាដែលមានគេជាអនុភាពម្ដេចក៏ទុកនាងឲ្យវេទកម្មអ្វីដល់ម្ទេះ? ម្ដេចក៏មិនរំលាយជីវិតនាងនៅគ្រាដែលទៅមើលប្រាសាទអង្គរទៅ?...អង្គរ? នាងនឹកឡើងសែនគ្នាន់ក្នាញ់ក្ដៅពេល ដូចឃើញនៅនឹងមុខថ្មីៗ។ យីអាណោស៊ិតនេះ ចំជាព្រហើន ថ្វើមធំមែនហើយហ្ន៎! វាហ៊ានទៅរលុករលុយឯងកំពុងថ្វាយបង្គំព្រះអង្គ។ នាងនឹកឃើញវេលាដែលឡើងជិះរទេះមកទាំងភ្លៀង នាងនឹកឃើញកាលដែលនាងដេកញ័រកន្ទ្រាក់ទទូរផ្ទួយពីរ បីជាន់ដោយនាងចាប់គ្រុនយ៉ាងធ្ងន់។ នាងនឹកឃើញដល់នាងសុចិត្រាដែលជួយបីបាច់ថែរក្សានាងក្នុងពេលនោះ។ នាងនឹកដល់ថៅកែបេងជុន ដែលរត់រកពេទ្យទាំងរាត្រី ដើម្បីយកថ្នាំមកចាក់ឲ្យនាង...លុះតែនាងបានគ្រាន់ស្រយាល។ ឱបើប្រសិនណាជានាងមានសំណាងទៅថ្ងៃក្រោយ នាងនឹងមិនភ្លេចគុណជនទាំងពីរនាក់នេះឡើយ។

លុះឃើញថានាងបានគ្រាន់ស្រួលបួលបន្តិចហើយ ម្ដាយនាងក៏បាននាំនាងវិលមកផ្ទះសំបែងវិញដោយរួសរាន់។ ចំណែកយាយនួនដែល មានព្រួយដោយខ្លាចក្រែងទាស់

អត្ថបទដោយ៖ កញ្ញា មាស សុភាព

អធ្យាស្រ័យនៃនាងថូ ព្រោះយល់ឃើញថាកូនគាត់មានកិរិយាមិនគប្បីក្នុងកំពែងអង្គរធំនោះ គាត់ក៏បានទៅនិយាយសុំចិត្តកុំឲ្យនាងថូគេចាប់ថ្នាក់ប្រកាន់អ្វីសោះឡើយ។ ស្ត្រីនោះឮហើយក៏សើចកាច់កក្អាកក្អាយហើយថា ចៃកុំព្រួយអីយ៉ាងនោះក្មេងនៅព្រហ្មចារីតែងអៀនគូស្រករយ៉ាងនេះឯង។ យាយនួនគាត់បានធូរដើមទ្រូងពីរឿងនេះ ហើយក៏ពាំសំដីនេះដោយមានទឹកមុខរីករាយ មកប្រាប់កូនគាត់ភ្លាម។

នាងវិធារីដែលអង្គុយក្នុងយប់ស្ងាត់ កាលបើនឹកឃើញកិរិយាយ៉ាងនេះនៃម្ដាយនាងហើយ នាងក៏សែនក្នាញ់តូចចិត្ត ដោយនឹកខ្មាសគេពន់ប្រមាណ។នាងមានចំបែងជាអនេក។ បានពេលណា នាងរៀបតែរបូតមាត់ជំរាបម្ដាយពីហេតុដែលនាងស្អប់ឈ្មោះណៃស៊ិត តែសេចក្ដីអៀន និងដំណើរទាស់ខុសប្រពៃណីមកសង្កត់អណ្ដាតនាងឲ្យស្ងៀមទៅវិញ ព្រោះយល់ឃើញថាតាំងពីបុរាណនាយមក ស្ត្រីខ្មែរមិនមានអំណាចរើសប្ដីលើខ្លួនឯងទេ។ បើឪពុកម្ដាយទុកដាក់ល្អអាក្រក់ដូចម្ដេច ក៏ត្រូវតែទទួលយកជានិច្ច។ ទំលាប់យ៉ាងនេះ នាងយល់ឃើញថា ជាការមិនប្រកបនឹងយុត្តិធម៌សោះ។ ព្រះឥន្ទ្រ ព្រះព្រហ្ម ដែលមានឫទ្ធានុភាពក្រៃលែង ម្ដេចឡើយក៏មិនមកជួយខ្ញុំឲ្យផុតពីទុក្ខទម្ងន់នេះចេញ? ឱបងប៊ុនធឿនសំឡាញ់អើយ! ទ្រូងអូនគ្មានធូរស្បើយវេលាណាទេ។ បើនៅតែចុកណែនអួលផ្សាយ៉ាងនេះទៅ ឃើញថានឹងធន់ធារមិនបានយូរប៉ុន្មានឡើយ។

នាងវិធារីនៅត្រាំក្នុងទុក្ខសង្រេងយ៉ាងនេះ ទាល់តែឮមាត់ក្អែក ដែលប្រស្រ័យនៅដោយចុងអម្ពិល តាមជួរមាត់កំពង់ ស្រែកខ្វកឡើងទ្រហឹងអឹងអាប់។ នាងងាកទៅខាងកើតក៏ឃើញពន្លឺព្រាងៗ របស់ព្រះសុរិយាដែលរះបំភ្លឺលោក។ នាងក្រោកឡើយមានដៃជើងរួយស្រពន់ ហើយដើរទៅបើកមុងចូលដំណេក។

នាងវិធារី កើតទុក្ខឥតដំណេកអង្គុយយ៉ាងនេះសព្វទិវារាត្រី។ ខ្លួននាងល្វិតល្វៃស្គមនៅតែស្បែកដណ្ដប់ឆ្អឹង។ យាយនួនឃើញដូច្នេះហើយ ក៏បង្ខំឲ្យខាងប្រុសគេរៀបចំឲ្យបានក្នុងពេលឆាប់ ដើម្បីឲ្យបុត្រីគាត់បានស្វាមីហើយនឹងអាលនាំគ្នាដើរលេងកំសាន្តរំហែចិត្ត។ ដូច្នោះហើយនាងថូ ដែលសមចិត្ត និងគំនិតយ៉ាងនេះផងក៏ប្រើគូលីមកជំរះស្មៅយកទីកន្ទែងទុកធ្វើរោងផ្កាស្លា រោងចុងភៅ ហើយដញ្ជូនដើមស្លានៅទាំងមូលខ្លះ ពុះជារនាបខ្លះ ព្រមទាំងស្បូវកណ្ដាបដែលយកបង្គរទុកបំរុងជាស្រេច។

អត្ថបទដោយ៖ កញ្ញា មាស សុភាព

នាងវិធាវីកាលបើឃើញវត្ថុទាំងនោះហើយ ក៏រឹតតែសុបសៅខ្លាំងឡើងៗ។ នាងលែងចេញវាចាស្ដីថាអ្វីសោះ បើគេដេញដោលសួរពីសុខពលនាងច្រើនពេក នាងក៏ញញឹមដោយស្រពោន ហើយបែរមុខចេញទៅ។

ប្រហែលពីរបីថ្ងៃមក ចាប់មានក្អកស្ងួតមកអម្រួនដើមទ្រូងឲ្យនាងឈឺផ្សារអស់ប្រាណ។ នៅព្រហាមយប់មួយដែលឥតបាននិទ្រាសោះ ស្រាប់តែនាងក្អកឃុះមកមានធ្លាក់លោហិតស្រស់ៗ គេយកកន្ថោរមកត្រងឈាមនោះបានចំនួនពីរពែងៗ ឯនាងអស់កំលាំងពេក ក៏ដួលស្រប៉ូបនៅត្រង់កន្លែងអង្គុយ។

យាយនួន និងយាយផៃ ភ័យស្រឡាំងកាំង ក៏នាំគ្នាលើកគ្រាហ៍នាងវិធាវី ទៅដាក់លើគ្រែ ហើយម៉ែផៃរត់ទៅពឹងអ្នកជិតខាងម្នាក់ឲ្យគេអាណិត ទៅអញ្ជើញគ្រូពេទ្យមកជាប្រញាប់។

នៅពេលដែលគ្រូពេទ្យមកដល់ នាងវិធាវីនៅតែស្តូកស្ដឹងមិនទាន់ដឹងខ្លួននៅឡើយ។ គ្រូពេទ្យចូលទៅចាប់ដៃ ឆ្វេងអ្នកឈឺមកពិនិត្យជីពចរ ហើយយល់ថាស្ត្រីក្រមុំនេះមានកម្លាំងខ្សោយពេកណាស់។ ដូច្នេះហើយ គេបើកប្រអប់យកថ្នាំមួយបំពង់មកចាក់ឲ្យ ទើបគេនិយាយសុំឲ្យអ្នកជំងឺទៅសម្រាកកម្លាំងកុំឲ្យមានផលរមាស់ ឬមានអ្នកណាធ្វើឲ្យឃ្នើសចិត្តអ្វីឡើយ។

លុះគ្រូពេទ្យចុះទៅបានមួយស្របក់ នាងវិធាវិក៏ភ្ញាក់ដឹងខ្លួនឡើង។ យាយនួនគាត់អររខិបរខុប លើកបបរ និងត្រីងៀតដែលបំរុងទុកមកឲ្យនាងអាស្រ័យ។ យុវតីនេះឮម្ដាយលួងលោមឲ្យញុំាពេក ក៏កើតមានចិត្តអាណិត ហើយខំត្រដរមកអង្គុយជិតម្ដាយ ទើបលើកស្លាបព្រាចូកអាហារ។ នាងទើបតែនឹងលេបបានពីរបីមាត់ប៉ុណ្ណោះស្រាប់តែមានរថយន្តមួយបើកមកឈប់នៅមុខផ្ទះ ហើយគេឃើញនាងថូចុះប្រញិបប្រញាប់មកស្រែកពីចម្ងាយ។

ចែអើយ ចែ ខ្ញុំទើបឮគេនិយាយអំបាញ់មិញនេះសោះ។ នាងវិធាវី ឮសូរមាត់នោះក៏ងាកមើលទៅ ស្គាល់ជានាងថូក៏នឹកអួលក្នាញ់ភ្នាម។ សម្បុរមុខនាងឡើងក្រហមច្រាលដោយសេចក្ដីខឹង ឯរោគក្អកក៏ងើបឡើងទាញអម្រួនខ្លួននាង។ លុះនាងស្ដោះទៅក្នុងកន្ថោរ គេឃើញធ្លាក់សុទ្ធតែឈាមក្រហមឆ្អៅ។

ឃើញដូច្នោះហើយ នាងថូក៏ស្ទុះទៅត្រកងនាងវិធាវី:

អត្ថបទដោយ៖ កញ្ញា មាស សុភាព

*យីក្មួយអញឈឺអីដល់យ៉ាងនេះហ្ន៎? ចែបានអញ្ជើញគ្រូណាមើលហើយ ឬនៅ? យាយនួនដែលភ័យស្ទើរគ្មានស្មារតីនោះ ក៏ហាមាត់ឆ្លើយឡើងទាំងប៉ប៉ិបប៉ប៉ុប។*

*គ្រូពេទ្យបារាំងគេទើបនឹងចុះទៅមុន នាងអញ្ជើញមកដល់បន្តិចនេះ។*

*ឱចែកុំរកពេទ្យ! ពេទ្យគេមើលមិនពូកែដូចគ្រូខ្មែរទេ។ ខ្ញុំស្គាល់លោកាសង្ឃមួយអង្គដែលតែចង្រ្កមការនា នៅក្នុងគុហាភ្នំសំពៅ។ លោកចេះមន្តវិជ្ជាពូកែណាស់។ លោកធ្វើទឹកមន្តឲ្យភ្លូត បើបានផ្លូតទឹកម្តងនឹងឃើញស្បើយ បីដងនឹងជាស្រឡះ។*

*យីលោកនៅឆ្ងាយអីម៉្លេះ តើបានរណាគេទៅនិមន្តលោកមក?*

*ចែព្រួយអី ឡានខ្ញុំឈឹបទៅឈឹបមក ពីនេះទៅភ្នំសំពៅឆ្ងាយប៉ុន្មាន!*

*យាយនួនក៏ស្រែកហៅម៉ែផៃឲ្យដកហូត ពីខ្វាក់យកទៀនមួយគូ និងធូបមួយសំណុំមកជូននាងថូ។ ស្ត្រីនេះក៏ម្នីម្នាចុះទៅថា ដើម្បីនឹងចាត់ចែងឲ្យគេទៅនិមន្តព្រះសង្ឃពូកែនោះមក។*

*នៅល្ងាចត្រជាក់ ឡាននាងថូក៏ត្រឡប់មកឈប់នៅមុខផ្ទះយាយនួនវិញ ស្ត្រីនេះឃើញហើយ ក៏មានវាចារទៅកាន់ជនម្នាក់ក្នុងបណ្តាភ្ញៀវទាំងឡាយ ដែលមកសួរដំណឹងត្រៀបត្រា ឲ្យចុះទៅអារាធនាភិក្ខុឡើងលើផ្ទះ។ ព្រះសង្ឃរូបនេះមានវ័យចាស់គ្រាន់បើហើយ ដំណើរកោងច្រត់ទៅលើឈើមួយ ហើយមានសាច់ជ្រីវជ្រោកដណ្តាប់ ដោយចីពរជ្រលក់ខ្ទឹមខ្នុរ។*

*លុះគេបាននិមន្តលោកឲ្យឡើងរួចហើយ លោកក៏មកគង់កន្ទេលមួយដែលគេរៀបបំរុងជាមុន។ ក្រោយដែលគេលើកទឹកតែ បារី ម្លូ ស្លាមកប្រគេនលោក លោកក៏មានថេរដីកាសួរដោយសំដីស្អកៗមួយៗ៖*

*ញោមនិមន្តអាត្មាមកនេះ តើមានការដូចម្តេចខ្លះ?*

*យាយនួនគាត់ក៏ខិតចូលជិត ហើយនិយាយពិតលោកតាមដំណើរ។ ភ្ញៀវម្នាក់ដែលនៅជិតខាងក៏លើកថាំងមកដាក់ទឹកពេញមកប្រគេនលោក។ ក្នុងភាជន៍មានផ្កាម្លិះក្រពុំៗអណ្តែតសក្បុស។ លោកយកធូបបីសរសៃមកផ្គុំគ្នានឹងដុំក្រមួនមួយប៉ុនកូនដៃ ហើយយកទៅបិទភ្ជាប់នឹងមាត់ផុងទឹក។*

***(សូមរង់តាមដានរឿង ផ្កាស្រពោន ភាគទី១៣ នៅសប្តាហ៍ក្រោយ)***

*អត្ថបទដោយ៖ កញ្ញា មាស សុភាព*